**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា នៃឈូងសមុទ្រ កម្ពុជា - ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ ទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃ ទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ ៖

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | **ប៊ិន** | **ឈិន** | ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម | **វ៉ា** | **គឹមហុង** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន | អនុប្រធាន |
| ៣- | ឯកឧត្តម | **ស៊ុយ** | **សែម** | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៤- | ឯកឧត្តម | **ហូ** | **មិថិត្រ** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | អនុប្រធាន |

www.pheakdeylaw.com

| | | | | | |
|---|---|---|---|---|---|
| ៥- | ឯកឧត្តម | ហេង | ចន្ទ្រម៉ុនិនាត | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា | ទីប្រឹក្សាជាន់ខ្ពស់ |
| ៦- | ឯកឧត្តម | ច័ន្ទ | សានី | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ទីប្រឹក្សាជាន់ខ្ពស់ |
| ៧- | ឯកឧត្តម | ឡុង | វិសាលោ | ឯកអគ្គរាជទូតប្រចាំព្រះរាជាណាចក្រថៃ | សមាជិក |
| ៨- | ឯកឧត្តម | ឡាំ | ជា | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៩- | ឯកឧត្តម | វង្សី | វិស្សុត | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- | ឯកឧត្តម | គីមរ៉ែត | សំរេច | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១- | ឯកឧត្តម | ហ៊ីង | ថូរ៉ាក់ស៊ី | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២- | ឯកឧត្តម | សុខ | ខាវ៉ាន់ | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- | ឯកឧត្តម ឧត្តមនាវី | ទៀ | វិញ | មេបញ្ជាការកងទ័ពជើងទឹកនិងជាអគ្គលេខាធិការគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | សមាជិក |
| ១៤- | ឯកឧត្តម | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៥- | ឯកឧត្តម | ឆា | ដុប | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៦- | ឯកឧត្តម | កៅ | ឆារ៉ូ | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៧- | ឯកឧត្តម | គុណា | ញឹម | អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | |
| ១៨- | ឯកឧត្តម | ជៀប | សួរ | អគ្គនាយកប្រេងកាត នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៩- | ឯកឧត្តម | គង់ | ច័ន្ទទាសនា | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |
| ២០- | ឯកឧត្តម | ហាក់ | សុខហេង | អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | លេខាធិការ |

**ប្រការ២:** គណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាតនៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នា កម្ពុជា- ថៃ មានភារកិច្ច ៖

(ក)- ចរចារៀបចំសន្ធិសញ្ញា ប្រព័ន្ធច្បាប់គ្រប់គ្រងបទប្បញ្ញត្តិ គោលការណ៍ លិខិតបទដ្ឋាន ទាំងឡាយពាក់ព័ន្ធនឹងការអភិវឌ្ឍរួមគ្នា នៃធានធានប្រេងកាត ដែលមានផលប្រយោជន៍ទៅវិញទៅមក និងអាចទទួលយកបាន ដោយភាគីទាំងពីរ ក្នុងការបែងចែកការចំណាយ និងផលចំណេញ នៃការធ្វើអាជីវកម្មធនធានប្រេងកាត ដែលស្ថិតនៅក្នុងតំបន់នៃការអភិវឌ្ឍរួមគ្នា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

(ខ)- ចរចារៀបចំសន្ធិសញ្ញា កំណត់ព្រំដែនសមុទ្រ ដែនជីខ្ពង់រាបបាតសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលស្ថិតចន្លោះបន្ទាត់ នៃការទាមទារអះអាងដែនសមុទ្របច្ចុប្បន្នរៀងៗខ្លួន របស់ប្រទេសទាំងពីរ

www.pheakdeylaw.com

នៅក្នុងតំបន់ដែលត្រូវបែងចែកព្រំដែន អនុលោមទៅតាមបណ្តាគោលការណ៍ទាំងឡាយ ដែលអាចអនុវត្តបាននៃច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

(គ)- ផ្អែកលើតម្រូវការចាំបាច់ គណៈកម្មាធិការបច្ចេកទេសចម្រុះគ្នានេះ ត្រូវចុះអង្កេតផ្ទៀងផ្ទាត់រួមគ្នា លើនិយាមការ (កូអរដោណេ) នៃកោះ ថ្មប៉ប្រះទឹក ចំណុចនីមួយៗ និងអ្វីៗទាំងអស់ ដែលមានលក្ខណៈពិសេស និងចរឹតប្រវត្តិសាស្ត្រពាក់ព័ន្ធ ស្ថិតនៅក្នុងដែនដីគោក និងដែន សមុទ្រកម្ពុជា ថៃ។

(ឃ)- តាមដាន និងត្រួតពិនិត្យ ការអនុវត្តសន្ធិសញ្ញា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋាននានា។

**ប្រការ៣** : គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ ត្រូវជួបប្រជុំគ្នាឱ្យបានទៀងទាត់ ក្នុងទស្សនៈសម្រេច ឱ្យបាននូវការងាររបស់ខ្លួន ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ ឱ្យបានឆាប់រួសរាន់។ គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ អាចបង្កើតឡើងនូវអនុគណៈកម្មាធិការ ឬ ក្រុមការងារ ដូចអ្វីដែលសមស្របទៅនឹងតម្រូវការចាំបាច់។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចម្រុះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន ហើយគណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញទីប្រឹក្សា និងអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ និងត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាល លើលទ្ធផលការងាររបស់ខ្លួន។

**ប្រការ៥** : គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៦**: គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ មានសិទ្ធិប្រើប្រាស់មូលនិធិដែលជាចំណូលពីវិស័យ ប្រេងកាតនៃក្រសួងរ៉ែនិងថាមពល ក្នុងការបំពេញការងាររបស់ខ្លួន តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ៧** : សេចក្តីសម្រេចលេខ ១៤៨ សសរ ចុះថ្ងៃ ទី ២៨ ខែតុលា ឆ្នាំ២០១៤ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com